បណ្ណព័ត៌មានអំពីជំងឺឆ្លង

# ជំងឺគ្រុនពោះវៀន

*ជំងឺគ្រុនពោះវៀនគឺបណ្តាលដោយការឆ្លងបាក់តេរីសាលម៉ូនេឡាថៃហ្វី។ នៅក្នុងប្រទេសអូស្ត្រាលី ការកើតជំងឺគ្រុនពោះវៀនភាគច្រើនគឺឆ្លងមកពីបរទេស ហើយកើតមានក្រោយពីទទួលទានអាហារឬទឹកដែលមានមេរោគជំងឺនេះ នៅក្នុងប្រទេសទាំងឡាយដែលសំបូរដោយជំងឺគ្រុនពោះវៀន។*

## តើជំងឺគ្រុនពោះវៀនគឺជាអ្វី?

ជំងឺគ្រុនពោះវៀនគឺបណ្តាលដោយការឆ្លងបាក់តេរី*សាលម៉ូនេឡាថៃហ្វី* (*Salmonella Typhi*) ។ នៅក្នុងប្រទេសអូស្ត្រាលី ការកើតជំងឺគ្រុនពោះវៀនភាគច្រើនគឺឆ្លងមកពីបរទេស ហើយកើតមានឡើងក្រោយពីទទួលទានអាហារឬទឹកដែលមានមេរោគនៃជំងឺនៅក្នុងប្រទេសទាំងឡាយដែលសំបូរដោយអ្នកកើតជំងឺគ្រុនពោះវៀន។ ការឆ្លងបាក់តេរីនេះមិនដូចគ្នានឹងការឆ្លងបាក់តេរី*សាលម៉ូនេឡា*ឡើយ។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

អ្នកកើតជំងឺគ្រុនពោះវៀនអាចជួបប្រទះនឹងរោគសញ្ញាមិនសូវធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរ។ រោគសញ្ញាទាំងឡាយនៃជំងឺគ្រុនពោះវៀនអាចមានរួមទាំងគ្រុនក្តៅ ឈឺក្បាល ភាពមិនសុខស្រួលជាទូទៅ មិនឃ្លានចំណីអាហារ និងក្អកស្ងួត។ ចង្វាក់បេះដូងមានដំណើរយឺត ហើយសរីរាង្គអណ្តើកឡើងរីកធំ។ អ្នកខ្លះមានស្នាមពណ៌ផ្កាឈូកនៅលើដងខ្លួន។ ការទល់លាមកឬរាករូសអាចកើតមានឡើង។ រោគ សញ្ញាទាំងឡាយចាប់ផ្តើមនៅពេល 1 ទៅ 3 អាទិត្យក្រោយពីឆ្លងរោគនេះមក។ អ្នកខ្លះគ្មានរោគសញ្ញាអ្វីឡើយ។

## តើជំងឺនេះឆ្លងតាមរបៀបណា?

នៅក្នុងប្រទេសអូស្ត្រាលី ជាធម្មតាជំងឺគ្រុនពោះវៀនឆ្លងមកពីប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដូចជាប្រទេសឥណ្ឌូនេស៊ីជាដើម និងបណ្តាប្រទេសនៅក្នុងឧបទ្វីបឥណ្ឌា។ មនុស្សភាគច្រើនកើតជំងឺគ្រុនពោះវៀនតាមរយៈការទទួលទានអាហារឬទឹកដែលចម្លងមេរោគដោយអ្នកកើតជំងឺនេះ ដោយមានរួមទាំងអ្នកដែលគ្មានរោគសញ្ញាណាមួយឡើយ។ បន្លែផ្លែឈើស្រស់ ទឹកដោះគោឆៅ និងពពួកសត្វខ្យងខ្ចៅលៀសគ្រំឆៅ គឺជាប្រភេទអាហារដែលមានទំនាក់ទំនងញឹកញាយបំផុតជាមួយនឹងជំងឺនេះ។

## តើអ្នកណាដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

ជនរាល់រូបអាចកើតជំងឺគ្រុនពោះវៀន ប៉ុន្តែមានថ្នាំបង្ការរោគ ហើយអ្នកធ្វើដំណើរទៅកាន់បណ្តាប្រទេសដែលសំបូរដោយជំងឺគ្រុនពោះវៀនគួរចាក់ថ្នាំបង្ការរោគ។ មណ្ឌលគ្រប់គ្រងជំងឺ (Centers of Disease Control) (www.cdc.gov) មានឱវាទ អំពីការធ្វើដំណើរ។

អ្នកប៉ះពាល់នៅផ្ទះជាមួយ ឬអ្នកដែលបានធ្វើដំណើរជាមួយអ្នកកើតជំងឺគ្រុនពោះវៀន នឹងទទួលការពិនិត្យពិច័យរកមើលជំងឺគ្រុនពោះវៀនដោយផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់ខ្លួន។ អ្នកប៉ះពាល់ទាំងឡាយគួរដឹងអំពីរោគសញ្ញានៃជំងឺគ្រុនពោះវៀន ហើយគួរទៅជួបវេជ្ជបណ្ឌិតរបស់ខ្លួន បើកើតមានរោគសញ្ញាទាំងឡាយ។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

អ្នកធ្វើដំណើរទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយគួរចាក់ថ្នាំបង្ការរោគ មុននឹងធ្វើដំណើរ ហើយៈ

- ចៀសវាងការបរិភោគអាហារឆៅ ដោយមានរួមទាំងផ្លែឈើ លុះត្រាតែអាចបកសំបកនៃផ្លែឈើនោះបាន
- ចៀសវាងការទទួលទានទឹកឆៅ ដោយមានរួមទាំងទឹកកក
- ទទួលទានភេសជ្ជៈពីកំប៉ុងឬប្រអប់ដាក់ដែលបិតជិត
- លាងសំអាតដៃក្រោយពីទៅបង្គន់ និងមុនពេលបរិភោគ
- ចៀសវាងការបរិភោគនៅតាមតូបលក់តាមចិញ្ចើមថ្នល់
- ធ្វើឲ្យប្រាកដថា អាហារក្តៅបានទទួលការចំអិនយ៉ាងម៉ត់ចត់ និងបរិភោគនៅពេលដែលអាហារនោះនៅក្តៅ។

មិនចាំបាច់ចាក់ថ្នាំបង្ការរោគសំរាប់ការធ្វើដំណើរនៅក្នុងប្រទេសអូស្ត្រាលីឡើយ។

អ្នកកើតជំងឺគ្រុនពោះវៀន ឬអ្នកដែលនៅក្នុងផ្ទះជាមួយនឹងអ្នកកើតជំងឺនេះ មិនត្រូវទៅធ្វើការទេបើការងាររបស់អ្នកទាំងនោះតំរូវឲ្យរៀបចំទុកដាក់ចំណីអាហារឬថែទាំកុមារ អ្នកជំងឺឬមនុស្សចាស់  ហើយមិនគួររៀបចំអាហារសំរាប់អ្នកដទៃឡើយ។ ការធ្វើតេស្តលាមកជាច្រើនដងនឹងត្រូវធ្វើឡើងដើម្បីឲ្យដឹងនូវពេលដែលលោកអ្នកគ្មានជំងឺនេះតទៅទៀត។ ផ្នែកសុខភាពសាធារណៈក្នុងតំបន់លោកអ្នកនឹងជំរាបលោកអ្នកអំពីពេលដែលលោកអ្នកអាចវិលទៅធ្វើការវិញ។

អ្នកដែលមានលទ្ធភាពឆ្លងរោគចេញពីប្រភពដូចគ្នា ឧទាហរណ៍ៈការធ្វើដំណើរទៅបរទេស ក៏នឹងទទួលឱវាទមិនឲ្យទៅធ្វើការផងដែរ បើការងាររបស់អ្នកទាំងនោះតំរូវឲ្យរៀបចំទុកដាក់ចំណីអាហារ ឬថែទាំកុមារ អ្នកជំងឺ ឬមនុស្សចាស់។ អ្នកទាំងនោះក៏នឹងត្រូវធ្វើតេស្តលាមករបស់ខ្លួនដែរ។

ដោយសារតែដៃអាចពាំនាំមេរោគនៃជំងឺគ្រុនពោះវៀនបាន ជាការសំខាន់ណាស់ក្នុងការលាងសំអាតដៃឲ្យបានម៉ត់ចត់ជានិច្ចក្រោយពីទៅបង្គន់ និងមុនពេលរៀបចំអាហារ។ គួរលាងសំអាតដៃជាមួយនឹងសាប៊ូនិងទឹករយៈពេលយ៉ាងតិច 15 វិនាទី  បន្ទាប់មកលាងជំរះដោយទឹក និងជូតសម្ងួតដៃឲ្យបានល្អ។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ដើម្បីធ្វើរោគវិនិច្ឆ័យជំងឺគ្រុនពោះវៀន  វេជ្ជបណ្ឌិតឬមន្ទីរពេទ្យក្នុងតំបន់លោកអ្នកនឹងបញ្ជូនសំណាកឈាមឬលាមកទៅឲ្យមន្ទីរពិសោធន៍ធ្វើតេស្ត។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

អ្នកកើតជំងឺគ្រុនពោះវៀនអាចចូលព្យាបាលនៅមន្ទីរពេទ្យ ហើយនឹងត្រូវការការព្យាបាលដោយប្រើថ្នាំអង់ទីប៊ីយោទិក។ អ្នកខ្លះប្រហែលជាគ្មានរោគសញ្ញាទាំងឡាយទេ ប៉ុន្តែអាចផ្ទុកមេរោគជំងឺនេះ។ អ្នកផ្ទុកមេរោគជំងឺនេះត្រូវព្យាបាលដោយប្រើថ្នាំអង់ទីប៊ីយោទិកផងដែរ។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

- វេជ្ជបណ្ឌិត  មន្ទីរពេទ្យ និងមន្ទីរពិសោធន៍ត្រូវរាយការណ៍ករណីនៃជំងឺគ្រុនពោះវៀនប្រាប់ផ្នែកសុខភាពសាធារណៈក្នុងតំបន់។

- បុគ្គលិកផ្នែកសុខភាពសាធារណៈនឹងធ្វើសម្ភាសន៍វេជ្ជបណ្ឌិតឬអ្នកជំងឺ(ឬអ្នកថែទាំ) ដើម្បីឲ្យដឹងនូវរបៀបដែលជំងឺនេះបានកើតមានឡើង។
- អាជ្ញាធរស្បៀងអាហាររដ្ឋ NSW (NSW Food Authority) ក្នុងកិច្ចសហការជាមួយ NSW Health ទទួលខុសត្រូវចំពោះការស៊ើបអង្កេតផ្នែកបរិស្ថានរបស់អ្នករៀបចំទុកដាក់អាហារដែលកើតជំងឺគ្រុនពោះវៀន។
- ផ្នែកសុខភាពសាធារណៈក្នុងតំបន់លោកអ្នកអាចផ្តល់ឱវាទបន្ថែមទៀតអំពីការហាមឃាត់មិនឲ្យទៅធ្វើការនិងទៅសាលារៀន។ អ្នកដែលគេហាមមិនឲ្យទៅធ្វើការនឹងត្រូវធ្វើតេស្តលាមកជាច្រើនលើក មុនពេលអនុញ្ញាតឲ្យវិលទៅធ្វើការវិញ។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

[www.health.nsw.gov.au](http://www.health.nsw.gov.au)